**LOWELL PUBLIC SCHOOLS**
ការិយាល័យរដ្ឋបាលកណ្ដាល Henry J. Mroz

155 Merrimack Street
Lowell, MA 01852

ថ្ងៃទី 22 ខែ ធ្នូ 2020

គោរពជូនសហគមន៍សង្កាត់សាលា Lowell Public Schools៖

ខ្ញុំសង្ឃឹមថា លោកអ្នក និង គ្រួសាររបស់លោកអ្នកមានសុវត្ថិភាពនិងមានសុខភាពល្អ នៅពេលដែលលោកអ្នកបានឃើញលិខិតនេះ ខណៈដែលយើងជិតឈានដល់ថ្ងៃឈប់សម្រាកហើយ។ ដោយសារវិស្សមកាលរដូវរងារដែលនឹងចាប់ផ្ដើមនៅពេលបញ្ចប់នៃថ្ងៃសិក្សានៅសាលានៅថ្ងៃពុធនោះ ខ្ញុំចង់ចែករំលែកជាមួយលោកអ្នកនូវបច្ចុប្បន្នភាពស្ដីពីទិន្នន័យជំងឺ COVID-19 ក្នុងមូលដ្ឋាន និង ពីរបៀបដែលយើងកំពុងបន្តពិនិត្យតាមដានទិន្នន័យនោះ ស្របពេលយើងកំពុងចារណាលើកាលបរិច្ឆេទដែលអាចទៅរួចណាមួយសម្រាប់បន្តការរៀនសូត្រដោយផ្ទាល់ឡើងវិញ។

ជារៀលរាល់ថ្ងៃព្រហស្បតិ៍ រដ្ឋ Massachusetts បានបញ្ចេញទិន្នន័យស្ដីពីជំងឺ COVID-19 តាមសហគមន៍របស់ខ្លួននៅលើគេហទំព័ររបស់រដ្ឋនេះ។ របាយការណ៍បច្ចុប្បន្នបំផុតបង្ហាញថា ទិន្នន័យជំងឺ COVID-19 នៅទីនេះក្នុងក្រុង Lowell និង នៅទូទាំងរដ្ឋ Massachusetts បន្តមាននិន្នាការងាកទៅរកទិសដៅអវិជ្ជមាន។ ចំនួនករណីប្រចាំថ្ងៃជាមធ្យមក្នុងអ្នកស្រុក 100,000 នាក់បានកើនឡើងទៅដល់ 134.4 នាក់ និង "អាត្រាករណីវិជ្ជមានគិតជាភាគរយ" (ភាគរយនៃការធ្វើតេស្តដែលវិជ្ជមាននៅទីនេះក្នុងក្រុង Lowell) បានកើនឡើងទៅដល់ 12.33% ។ ចំនួនទាំងពីរនោះបានកើនលើសយ៉ាងច្រើនពីកម្រិតកំណត់របស់រដ្ឋ Massachusetts ដែលត្រូវដាក់ក្រុង Lowell នៅក្នុងឋានៈជាក្រុងមានហានិភ័យខ្ពស់។ តាមការប្រៀបធៀប កាលពីពាក់កណ្ដាលខែតុលា អាត្រាករណីប្រចាំថ្ងៃជាមធ្យមរបស់ក្រុង Lowell គឺ 16.4 នាក់។ នៅពាក់កណ្ដាលខែវិច្ឆិកា អាត្រាករណីប្រចាំថ្ងៃគិតជាមធ្យមរបស់យើងគឺ 42.1 នាក់ ហើយអាត្រាវិជ្ជមានគិតជាភាគរយរបស់យើងគឺ 6.45% ។

សុខភាពនិងសុវត្ថិភាពរបស់សិស្សនិងបុគ្គលិកយើងចាំបាច់ត្រូវតែជាអាទិភាពនៅក្នុងគ្រប់ការសម្រេចដែលយើងធ្វើ ដូច្នេះ **នៅពេលសាលាបើកបផសនកាលឡើងវិញ ក្រោយពីវិស្សមកាលរដូវរងារនេះ នៅថ្ងៃ ចន្ទ ទី4 ខែ មករា ឆ្នាំ 2021 គ្រប់សិស្សនៅសង្កាត់សាលា Lowell Public Schools នឹងបន្តជាការរៀនសូត្រពីចម្ងាយ។**

កាលពីយប់មុន បន្ទាប់ពីប្រឹក្សាយោបល់ជាមួយគណៈកម្មការសុខភាព គណៈកម្មការសាលាបានកំណត់កាលបរិច្ឆេទគោលដៅដូចតទៅនេះសម្រាប់ឲ្យសិស្សវិលត្រលប់មកកាន់ការរៀនសូត្រដោយផ្ទាល់វិញ ប្រសិនបើទិន្នន័យ COVID-19 អាចប្រសើរឡើងពីពេលមួយទៅមួយ៖

- ថ្ងៃទី 1 ខែ កុម្ភៈ - សិស្សនៅក្នុងកម្មវិធីអប់រំពិសេសដាច់ដោយឡែកដែលកំពុងចូលរួមមធ្យោបាយរៀនសូត្រដោយផ្ទាល់ពីមុនរបស់យើង
- ថ្ងៃទី 1 ខែ មិនា - សិស្សដែលមិនស្ថិតនៅក្នុងការអប់រំពិសេសដាច់ដោយឡែក ប៉ុន្តែធ្លាប់ទទួលការបង្រៀនពីមុនដោយផ្ទាល់ក្នុងឆ្នាំសិក្សានេះ ជាផ្នែកមួយនៃផែនការដើមស្ដីពីការបើកសាលាឡើងវិញរបស់យើង
- ថ្ងៃទី 1 ខែ មេសា - ការពង្រីកមធ្យោបាយការរៀនសូត្រដោយផ្ទាល់របស់យើងដើម្បីរួមបញ្ចូលសិស្សបន្ថែមទៀត ក្រៅពីអ្នកដែលត្រូវបានចាត់ឲ្យធ្វើការរៀនសូត្រដោយផ្ទាល់នៅដើមឆ្នាំសិក្សានេះ។

កាលបរិច្ឆេទទាំងនេះមិនត្រូវបានកំណត់ជាអចិន្ត្រៃយ៍នោះទេ ហើយយើងនឹងបន្តពិនិត្យមើលទិន្នន័យ COVID-19 ឡើងវិញ និង ធ្វើការប្រឹក្សាយោបល់ជាមួយនឹងគណៈកម្មការសុខភាព ហើយយើងប្រាកដជានឹងផ្ដល់ជូនលោកអ្នកនូវបច្ចុប្បន្នភាពណាមួយ ខណៈពេលដែលយើងកំពុងមើលពិនិត្យមើលផែនការរៀនសូត្ររបស់យើងដំណើរការទៅមុខនោះ។ ទោះបីជាយើងនឹងមិនត្រលប់មកកាន់ថ្នាក់រៀនវិញដោយផ្ទាល់ដើម្បីចាប់ផ្ដើមឆ្នាំសិក្សា 2021 ក៏ដោយ យើងនឹងបន្តផ្ដល់ជូនសិស្សរបស់យើងនូវបទពិសោធន៍ការអប់រំមួយដែលមានន័យនិងសុវត្ថិភាពតាមវីដេអូអនឡាញ។

ដូចកាលពីមុនៗដែរ សូមចាំថាត្រូវបន្តគោរពតាមពិធីសារសុវត្ថិភាពដែលជួយកាត់បន្ថយការរីករាលដាលនៃជំងឺ COVID-19 ។ វារួមមានការរក្សាគម្លាតសង្គម ការពាក់ម៉ាស ការលាងដៃ ការមិនជួបជុំគ្នាជាក្រុមធំៗ និងការមិនបរិភោគអាហារ ផឹកភេសជ្ជៈ ឬ ប្រើស្លាបព្រា និង ប្រដាប់ប្រដាចម្អិនអាហារដដែលគ្នា។ នៅពេលយើងអាចធ្វើឲ្យចំនួនករណីជំងឺ COVID-19 របស់យើងប្រសើរឡើងនៅទីនេះក្នុងក្រុង Lowell បានកាន់តែឆាប់ យើងនឹងអាចឲ្យសិស្សត្រលប់មកកាន់អគារសិក្សារបស់យើងវិញបានកាន់តែលឿន។

នេះគឺជាឆ្នាំដ៏លំបាកមួយដោយមានហេតុផលខុសៗគ្នាជាច្រើន ដូច្នេះហើយ ខ្ញុំសូមអរគុណជានិច្ចសម្រាប់ការអត់ធ្មត់ ការបត់បែនតាមកាលៈទេសៈ និង ភាពជាដៃគូរបស់លោកអ្នកពេញមួយរយៈពេលមិនធ្លាប់មានកន្លងមកនេះ។

ខ្ញុំសូមជូនពរឲ្យលោកអ្នកមានសុភមង្គល និង សុខភាពល្អក្នុងឆ្នាំថ្មីខាងមុខនេះ។

Joel Boyd

បណ្ឌិត Joel D. Boyd
អ្នកគ្រប់គ្រងសង្កាត់សាលា